អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
# ពីសហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៣

សហព្រះរាជអាជ្ញាអន្តរជាតិ Brenda J. Hollis ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនេះផ្អែកតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ទាក់ទងនឹងស្ថានភាពបច្ចុប្បន្ននៃរឿងក្តី ០០៣ នៅចំពោះមុខ អ.វ.ត.ក។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានចេញ សេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី មាស មុត (រឿងក្តី ០០៣)។ ដូចក្នុងរឿងក្តី ០០៤/២ ដែរ អង្គជំនុំជម្រះជាថ្មីម្តងទៀត បានប្រឈមមុខជាមួយនឹងដីកាដំណោះស្រាយពីរខ្វែងគ្នា គឺដីកាមួយបានសម្រេចចោទប្រកាន់និងបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះ ខណៈដែលដីកាមួយទៀតសម្រេចលើកលែងចោទប្រកាន់ មាស មុត។ ជាថ្មីម្តងទៀត គឺមិនមានសំឡេងភាគច្រើនលើសលុបទេ ពោលគឺយ៉ាងហោចណាស់ត្រូវមានចៅក្រមបួនរូប តម្កល់ដីកាដំណោះស្រាយលើកលែងចោទប្រកាន់រឿងក្តីនេះ។ ទោះជាយ៉ាងណា គឺខុសពីរឿងក្តី ០០៤/២ ដោយហេតុថា ចៅក្រម អ.ប.ជ ទាំងប្រាំរូបក្នុងរឿងក្តីនេះ បានសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត មានសុពលភាព ប៉ុន្តែពុំមានសេចក្តីបង្គាប់ដោយសំឡេងភាគច្រើនលើសលុបដែលបញ្ជាក់ជាក់លាក់ឲ្យបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះទេ។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនបំពេញកិច្ចដោយសារពុំមានសំណុំរឿងនៅចំពោះមុខខ្លួន។ ហេតុដូច្នេះ ដោយហេតុថា អ.ប.ជ មិនបានបញ្ជូនរឿងក្តីនេះទៅអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើមួយទៅកាន់សហចៅក្រមស៊ើបអង្កេត ស្នើសុំឲ្យពួកគាត់បញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង។ សំណើនោះបានធ្វើឡើងផ្អែកលើការសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ អ.ប.ជ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើនេះ ដោយទុកឲ្យរឿងក្តី មាស មុត នេះ ស្ថិតក្នុងភាពមិនច្បាស់លាស់តាមផ្លូវតុលាការនៅដំណាក់កាលមុនជំនុំជម្រះ។

សហព្រះរាជអាជ្ញអាជ្ញាអន្តរជាតិបានជូនដំណឹង អ.ប.ជ ថា ខ្លួននឹងដាក់សំណើសុំមួយឲ្យអង្គជំនុំជម្រះដោះស្រាយចំពោះភាពមិនច្បាស់លាស់ផ្នែកតុលាការនេះ តាមរយៈការចេញសេចក្តីសម្រេចមួយដែលបិទបញ្ចប់កិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះនៅក្នុងរឿងក្តីនេះ ស្របតាមសេចក្តីសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ខ្លួន ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត មានសុពលភាព ឬស្របទៅនឹងអ្វីដែលត្រូវបានទទួលស្គាល់ថា ជាគោលជំហរស្វ័យប្រវត្តិ "ជាមូលដ្ឋាន និងជាកត្តាកំណត់" ដែលតម្រូវថា រឿងក្តីនេះត្រូវបន្តទៅជំនុំជម្រះ៕

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh